ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី

ខុទ្ទកាល័យ

# សេចក្តីថ្លែងការណ៍

## របស់

## ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៨ ក្រសួងហិរញ្ញវត្ថុរបស់សហរដ្ឋអាមេរិក បានចេញនូវសេចក្តីសំរេចមួយដាក់ពហិកាមកលើរូបឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** មេបញ្ជាការអង្គរក្សរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយចោទពីបទរំលោភសិទ្ធិមនុស្ស ហើយអាមេរិកនឹងមិនផ្តល់ទិដ្ឋាការអោយចូលទៅកាន់សហរដ្ឋអាមេរិកទេ ព្រមទាំងបង្កកទ្រព្យសម្បត្តិរបស់ឯកឧត្តម **ហ៊ីង ប៊ុនហៀង** ថែមទៀត ។

ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការថ្កោលទោសចំពោះវិធានការរបស់អាមេរិកនេះ ដែលធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋានមកលើរូប ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** ដែលជាអ្នកប្រតិបត្តិច្បាប់ដ៏ហ្មត់ចត់ និងជាអ្នកអនុវត្តន៍ភារកិច្ចដ៏ថ្លៃថ្នូរនៅក្នុងការការពារស្ថិរភាព និងសណ្តាប់ធ្នាប់សង្គមកម្ពុជា ដែលស្ថានភាពនេះកំពុងតែរីកចំរើនជាទីគាប់ប្រសើរ ។

អ្វីដែលអាមេរិកធ្វើនេះ គឺជាការបំពានអធិបតេយ្យនៃប្រទេសឯករាជ្យមួយ ដែលពុំស្ថិតនៅក្រោមច្បាប់របស់សហរដ្ឋអាមេរិកឡើយ ។ ហើយម្យ៉ាងទៀត គួរតែសួរទៅអាមេរិកវិញដែរថា ចុះកាលដែលកងទ័ពអាមេរិកមកសម្លាប់ជនជាតិកម្ពុជារាប់លាននាក់កាលពីទសវត្សរ៍ឆ្នាំ១៩៧០ ដែលគ្រាប់បែកនៅតែគេរកឃើញរហូតមកដល់សព្វថ្ងៃនេះ តើនេះមិនមែនជាការរំលោភសិទ្ធិមនុស្សពីសំណាក់អាមេរិកទេឬ ?

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការរិះគន់ដោយត្រង់ៗចំពោះវិធានការដោយខ្វះវិចារណញ្ញាណ និងជាអំពើបំពានទាំងកំរោលឥតអៀនខ្មាសរបស់សហរដ្ឋអាមេរិកមួយនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨

ខុទ្ទកាល័យ